## ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១២

## ជប៉ុនផ្តល់ ៩៧,៤៣៥ដុល្លារអាមេរិក សម្រាប់ការសាងសង់អគារសិក្សា



ក្រោមគ្រោងការណ៍នៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចរបស់ជប៉ុន ជំនួយឧបត្ថម្ភឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ(*ជំនួយគូសាណូណេ*) រដ្ឋាភិបាលជប៉ុនបានផ្តល់ជំនួយដែលមានទឹកប្រាក់សរុបចំនួន៩៧,៤៣៥ដុល្លាអាមេរិក ដល់អង្គការជីវិតថ្លៃថ្នូរ សម្រាប់គម្រោងសាងសង់អគារសិក្សាក្នុងសាលាបឋមសិក្សាអាញ្ញាសេះ និងសាលាបឋមសិក្សាពាម ក្នុងស្រុកថ្គង ខេត្តកំពង់ស្ពឺ។ កិច្ចសន្យាផ្តល់ជំនួយត្រូវបានចុះហត្ថលេខានៅថ្ងៃនេះដោយលោក កាវ៉ាមូរ៉ា ហ៊ីរ៉ុស៊ី ឧប ទូតស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និងលោកសាម អ៊ីន នាយកប្រតិបត្តិអង្គការជីវិតថ្លៃថ្នូរ នៅស្ថានទូតជប៉ុន។

ដើម្បីកែលម្អបរិស្ថានអប់រំ អង្គការជីវិតថ្លៃថ្នូរដែលជាអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកមួយនៅប្រទេសកម្ពុជា នឹងអនុវត្តគម្រោងសាងសង់អគារសិក្សា២ខ្នងដែលមួយខ្នងមាន៤បន្ទប់ និងមួយខ្នងទៀតមាន៥បន្ទប់រួមទាំងបំពាក់បរិក្ខារសិក្សានៅសាលាបឋមសិក្សាអញ្ញាសេះ និងសាលាបឋមសិក្សាពាមក្នុងស្រុកថ្គង ខេត្តកំពង់ស្ពឺ។ ជាផ្នែកមួយនៃគម្រោងនេះផងដែរ បន្ទប់ទឹកដែលមាន៤បន្ទប់នឹងត្រូវបានសាងសង់នៅក្នុងសាលាទាំងពីរនេះផងដែរ។ យើងរំពឹងថា សិស្សានុសិស្សជាង៤00នាក់នឹងអាចទទួលបានអត្ថប្រយោជន៍ពីការកែលម្អបរិស្ថានអប់រំនេះ។



កម្មវិធីគម្រោងជំនួយឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ(*ជំនួយគូសាណូណេ*)របស់រដ្ឋាភិបាលជប៉ុនបានចាប់ផ្តើមតាំងពីឆ្នាំ១៩៩១ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការអភិវឌ្ឍន៍ និងស្តាបនាប្រទេសឡើងវិញនៅកំរិតមូលដ្ឋាន។ ជំនួយនេះមានគោលបំណងការពារជនងាយរងគ្រោះពីកត្តាមួយចំនួនដូចជាភាពក្រីក្រ និងភាពអកុសលដែលអាចគំរាមកំហែងដោយផ្ទាល់ដល់ជីវភាពរស់នៅ ការចិញ្ចឹមជិវិត និងសេចក្តីថ្លៃថ្នូររបស់ពួកគេ ក៏ដូចជាជួយជុំរុញនូវភាពម្ចាស់ការលើខ្លួនឯងរបស់ប្រជាសហគមន៍។ ចាប់តាំងពីឆ្នាំ១៩៩១រដ្ឋាភិបាលជប៉ុនបានផ្តល់ថវិកាជាង៤៧លានដុល្លាអាមេរិកដល់អាជ្ញាធរមូលដ្ឋាន និង អង្គការក្រៅរដ្ឋាភិបាលដើម្បីអនុវត្តគម្រោងចំនួន ៤៦៤នៅទូទាំងប្រទេស។



*ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា*

*ទូរស័ព្ទ៖ ០២៣-២១៧-១៦១ ទូរសារ៖ ០២៣-២១៤-៣៣០*

*អ៊ីមែល: eco.jpn@.pp.mofa.go.jp*

*គេហទំព័រ: http://www.kh.emb-japan.go.jp*